ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 10 / 2015
ម៉ោង (Time/Heure): 15:28
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើសំណើរួមរបស់ក្រុមមេធាវីការពារក្តីសុំឲ្យពិចារណាឡើងវិញលើការអនុវត្តមួយចំនួន ពាក់ព័ន្ធនឹងចម្លើយនានា

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរួមមួយពីក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា ស្តីអំពីការអនុវត្តមួយចំនួនសម្រាប់ការសួរដេញដោលសាក្សី (“សំណើរួម”)[1]។ ក្រុមមេធាវីការពារក្តី ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកសេចក្តីណែនាំដែលបានចេញដោយអង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីសវនាការលើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូល កាលពីខែ កក្កដា ឆ្នាំ ២០១៥ ដែលបាន៖ (i) បង្គាប់ថាអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ពុំត្រូវផ្តល់ឯកសារចម្លងនៃចម្លើយពីមុនរបស់សាក្សីឱ្យទៅសាក្សីមុនពេលការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះទេ (ii) ភាគីពុំត្រូវសួរសំណួរនាំមុខនៅក្នុងប្រធានបទដែលមានលក្ខណៈចម្រូងចម្រាស និង (iii) ការតាំងសំណួរលើសាក្សី ពុំត្រូវធ្វើឡើងដោយគ្រាន់តែអាននូវអត្ថបទនៃចម្លើយពីមុនរបស់សាក្សីឱ្យគាត់ស្តាប់ ហើយធ្វើការបញ្ជាក់នោះទេ[2]។

## ២. សាវតារ និងសារណា

២. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីណែនាំសម្រាប់កិច្ចនីតិវិធីសវនាការបណ្តឹងសាទុក្ខខែ កក្កដា ឆ្នាំ ២០១៥ នៅក្នុងសំណុំរឿង ០០២/០១ ដែលនៅក្នុងសេចក្តីណែនាំនោះ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញពុំត្រូវផ្តល់ឯកសារចម្លងនៃចម្លើយពីមុនរបស់សាក្សីឱ្យទៅសាក្សី មុនពេលការមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការទេ[3] និងឱ្យអនុវត្តតាមសេចក្តីណែនាំដូចខាងក្រោមស្តីពីការប្រើប្រាស់ចម្លើយពីមុនរបស់សាក្សី៖

> លើកលែងតែមានការណែនាំពីអង្គជំនុំជម្រះ ការតាំងសំណួរលើសាក្សីពុំត្រូវធ្វើឡើងដោយគ្រាន់តែអាននូវអត្ថបទនៃចម្លើយពីមុនរបស់សាក្សីឱ្យគាត់ស្តាប់ ហើយធ្វើការបញ្ជាក់នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ចម្លើយពីមុនរបស់សាក្សីអាចត្រូវបានប្រើ

---

[1] សំណើរួមគ្នានៃមេធាវីការពារក្តីសុំឱ្យវិលមកប្រកាន់យកការអនុវត្តមួយចំនួនពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ឯកសារ E355 ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥។

[2] សំណើរួម កថាខណ្ឌ ១២។

[3] សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ (អ.ជ.ត.ក) ឯកសារ F26 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៥។

ប្រាស់*ក្នុងនោះ* ដើម្បីល្បងលើភាពអាចជឿជាក់បានរបស់សាក្សី ឬបញ្ជាក់អំពីភាពមិនស្របគ្នារវាងចម្លើយផ្សេងៗ[4]។

ពាក់ព័ន្ធនឹងការតាំងសំណួរទៅកាន់សាក្សីពីសំណាក់ភាគីនានា អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា ភាគី "ពុំត្រូវសួរសំណួរដែលមានលក្ខណៈនាំមុខ នៅក្នុងប្រធានបទដែលមានលក្ខណៈចម្រូងចម្រាស លើកលែងតែមានការអនុញ្ញាតពីអង្គជំនុំជម្រះ"[5]។ សំណើរួមនេះអះអាងថា អង្គ-ជំនុំជម្រះសាលាដំបូងគួរតែគោរពតាមទាំងស្រុងនូវនីតិវិធីកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល និងត្រូវបញ្ឈប់ជាបន្ទាន់នូវការអនុវត្តផ្ទុយរបស់ខ្លួន[6]។

៣. សហព្រះរាជអាជ្ញាឆ្លើយតបថា សំណើរួមគួរតែត្រូវបដិសេធចោល ពីព្រោះការអនុវត្តដែលអនុញ្ញាតឱ្យសាក្សីពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយពីមុនៗរបស់ខ្លួនឡើងវិញ មុននឹងផ្តល់សក្ខីកម្មនោះ ជំរុញឱ្យមាននូវប្រសិទ្ធភាព ភាពត្រឹមត្រូវ និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី ដែលការអនុវត្តបែបនេះ ត្រូវបានតុលាការព្រហ្មទណ្ឌអន្តរជាតិ "ទាំងអស់" ប្រតិបត្តិតាម[7]។ សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា ការអនុវត្តរបស់អង្គជំនុំជម្រះក្នុងការសួរសាក្សីឱ្យបញ្ជាក់ពីភាពត្រឹមត្រូវនៃចម្លើយពីមុនរបស់ពួកគាត់ គឺត្រឹមត្រូវតាមច្បាប់ និងមានប្រយោជន៍[8]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះបានអនុញ្ញាតឱ្យភាគីយោងទៅលើចម្លើយពីមុនសម្រាប់តែគោលបំណងមានកម្រិតប៉ុណ្ណោះ ពោលគឺដើម្បីធ្វើការបញ្ជាក់ ឬ ផ្តល់សេចក្តីពិស្តារបន្ថែមពីលើខ្លឹមសារនៃកំណត់ហេតុនោះ ដើម្បីរំឭកឡើងវិញនូវការចងចាំរបស់សាក្សី ឬ ដើម្បីតទល់ជាមួយនឹងសាក្សីអំពីភាពមិនស្របគ្នាទាំងឡាយ ឬ បើមិនដូច្នោះទេ ដើម្បីសាកល្បងអំពីភាពអាចជឿជាក់បានរបស់សាក្សី[9]។

---

[4] សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ (អ.ជ.ត.ក) ឯកសារ F26 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៥-៦។

[5] សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ (អ.ជ.ត.ក) ឯកសារ F26 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៥។

[6] សំណើរួម កថាខណ្ឌ ១១។

[7] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរួមរបស់ ខៀវ សំផន និង នួន ជា ទាក់ទងនឹងបែបបទនៃការសួរដេញដោយលសាក្សី ឯកសារ E355/1 ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ (ចម្លើយតបរបស់សហព្រះរាជអាជ្ញា) កថាខណ្ឌ ២, ១០-១៤។

[8] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២, ១៥។

[9] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២, ១៦-១៧។

01156626



៤. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបថា អង្គជំនុំជម្រះគួរតែបដិសេធសំណើរួមនេះ និងរក្សាការអនុវត្តបច្ចុប្បន្នរបស់អង្គជំនុំជម្រះដែលអនុញ្ញាតឱ្យសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីពិនិត្យឡើងវិញលើចម្លើយពីមុនរបស់ខ្លួន មុនពេលពួកគាត់ផ្តល់សក្ខីកម្ម ព្រមទាំងស្នើសុំឱ្យធ្វើការបញ្ជាក់ឱ្យច្បាស់អំពីនីតិវិធីស្តីពីការប្រើប្រាស់ចម្លើយពីមុនៗ ក្នុងអំឡុងពេលសួរដេញដោលសាក្សី[10]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា សេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល មិនមានសំអាងហេតុឡើយ ហើយសេចក្តីណែនាំទាំងនេះចេញ ដោយមិនប៉ះពាល់ដល់មូលដ្ឋាននៃបណ្តឹងសាទុក្ខដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីទេ[11]។ សហមេធាវីនាំមុខ អះអាងបន្ថែមទៀតថា ការហាមឃាត់សាក្សីមិនឱ្យអានចម្លើយពីមុនៗរបស់ពួកគាត់ មុនពេលពួកគាត់ចូលមកផ្តល់សក្ខីកម្មនៅក្នុងតុលាការនោះ នឹងបណ្តាលឱ្យមានការពន្យារពេលដែលមិនចាំបាច់ ហើយថា ការហាមឃាត់ជាទូទៅលើការសួរសំណួរនាំមុខបែបនេះ នឹងធ្វើឱ្យប៉ះពាល់ដល់នីតិវិធីការដេញដោលតាមប្រព័ន្ធស៊ីវិលរបស់ អ.វ.ត.ក[12]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ក្នុងវិសាលភាពដែលក្រុមមេធាវីការពារក្តីស្នើថា ភាគីគួរត្រូវបានអនុញ្ញាតឱ្យធ្វើការជំទាស់ដោយមានសំអាងហេតុទៅនឹងសំណួរនាំមុខនោះ ការអនុវត្តបែបនេះត្រូវបានបង្កើតឡើងរួចហើយដោយអង្គជំនុំជម្រះសាលាដំបូង ហើយក្រុមមេធាវីការពារក្តីពុំបានបង្ហាញថាតើ ការអនុវត្តបែបនេះប៉ះពាល់ដល់មេធាវីការពារក្តីបែបណានោះឡើយ[13]។

## ៣. ក្របខណ្ឌច្បាប់ និងសំអាងហេតុ

៥. ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់ជាច្រើនដងហើយនៅក្នុងសំណុំរឿង ០០២ សាក្សីត្រូវបានអនុញ្ញាតឱ្យពិនិត្យឡើងវិញលើចម្លើយពីមុនៗរបស់ខ្លួន មុនពេលផ្តល់ សក្ខីកម្ម ហើយអាចត្រូវបានស្នើឱ្យបញ្ជាក់ពីភាពត្រឹមត្រូវនៃចម្លើយពីមុនរបស់ពួកគាត់ នៅពេលពួកគាត់ចាប់ផ្តើមផ្តល់សក្ខីកម្ម[14]។

---

[10] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើរួមរបស់ក្រុមមេធាវីការពារក្តី ស្តីពីការអនុវត្តមួយចំនួន ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញ (សារណាតបសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី) ឯកសារ E355/2 ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ ទំព័រ ២០។

[11] សារណាតបសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤។

[12] សារណាតបសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៧, ២៥។

[13] សារណាតបសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២០, ២៥-២៦។

[14] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា៖ "ការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយ ភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ

នៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធសំណើរបស់មេធាវីការពារក្តី នួន ជា ដែលបានស្នើឲ្យអង្គជំនុំជម្រះបោះបង់ចោលការអនុវត្តបែបនេះ[15]។ សំណើរួមរបស់ក្រុមមេធាវីការពារក្តី ស្នើសុំជាថ្មីម្តងទៀតឲ្យអង្គជំនុំជម្រះបោះបង់ចោលការអនុវត្តបែបនេះ ហើយលើកនេះគឺផ្អែកទៅលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធនឹងនីតិវិធីសវនាការបណ្តឹងសាទុក្ខ នាខែ កក្កដា។

៦. ក្នុងខណៈដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើសេចក្តីសម្រេចចុងក្រោយទៅលើអង្គច្បាប់ និងអង្គហេតុ[16] អង្គជំនុំជម្រះសាលាដំបូងទទួលបន្ទុកអនុវត្តកិច្ចដំណើរការនីតិវិធីរបស់ខ្លួន និងមិនជាប់កាតព្វកិច្ចអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានបង្កើតឡើងជាក់លាក់សម្រាប់ស្តាប់សក្ខីកម្មសាក្សី ក្នុងសវនាការលើបណ្តឹងសាទុក្ខនោះឡើយ។ ការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល មិនសំដៅចំពោះអង្គជំនុំជម្រះសាលាដំបូងឡើយ ហើយអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា សេចក្តីណែនាំទាំងនេះ "ពុំមានអានុភាពទៅលើទឡ្ហីករណ៍ណាមួយ

---

វិច្ឆិកា ឆ្នាំ ២០១១" ឯកសារ E141 ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៧។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា៖ "សេចក្តីជូនដំណឹងទៅភាគី ពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺ ទាក់ទងនឹងការប្រើប្រាស់ឯកសារនានាក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី (ឯកសារ E201)" ឯកសារ E201/2 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ១។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៧។ សាលក្រម សំណុំរឿង ០០២/០១ ឯកសារ E313 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៣១។ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ឯកសារ E336/3 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌទី ១៧ ពាក់ព័ន្ធនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការពិនិត្យមើលចម្លើយពីមុនរបស់ខ្លួន៖ "ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួនមានសិទ្ធិពិនិត្យ និងទទួលបានឯកសារសំណុំរឿងអនុលោមតាមវិធាន ៨៦ នៃវិធានផ្ទៃក្នុង រួមទាំងចម្លើយពីមុនៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ"។

[15] ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទំព័រ ៧៨ (ភាសាអង់គ្លេស)។ សូមមើល ផងដែរ សំណើរបស់ នួន ជា ពាក់ព័ន្ធនឹងការអនុវត្តមួយចំនួនដែលត្រូវមាន នៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-271 នាពេលខាងមុខ និងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀតក្នុងសំណុំរឿង ០០២/០២ ជាទូទៅ ឯកសារ E336 ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥។ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ឯកសារ E336/3 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥។

[16] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៦។

នៃបណ្តឹងសាទុក្ខដែលបានលើកឡើងដោយមេធាវីការពារក្តីឡើយ”[17]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការចេញសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលសម្រាប់នីតិវិធីសវនាការបណ្តឹងសាទុក្ខរបស់ខ្លួននោះ មិនមែនជាហេតុផលដែលមានអានុភាពសម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងបោះបង់ចោលនូវការអនុវត្តរបស់ខ្លួនដែលបានបង្កើតឡើងរួចហើយ ក្នុងការអនុញ្ញាតឱ្យសាក្សី ពិនិត្យឡើងវិញលើចម្លើយពីមុនៗរបស់ខ្លួន មុនពេលការផ្តល់សក្ខីកម្ម និងការសួរសំណួរដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃចម្លើយមុនៗរបស់ពួកគាត់ នៅពេលពួកគាត់ចាប់ផ្តើមផ្តល់សក្ខីកម្ម ដែលការអនុវត្តបែបនេះអនុលោមទៅតាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក[18]។

៧. លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់ថា ការផ្តល់ឱ្យសាក្សីនូវចម្លើយពីមុនៗរបស់ពួកគាត់មុនពេលពួកគាត់ចូលបង្ហាញខ្លួនក្នុងតុលាការនោះ គឺស្របគ្នាទាំងជាមួយនឹងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក (រួមទាំង វិធាន ២៥(២) នៃវិធានផ្ទៃក្នុង) និងជាមួយនឹងទម្លាប់អនុវត្តជាអន្តរជាតិ ហើយអង្គជំនុំជម្រះផ្តល់នូវសំអាងហេតុរបស់ខ្លួន នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសំណើរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ចំពោះបញ្ហានេះ[19]។

៨. ពាក់ព័ន្ធនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើឱ្យអង្គជំនុំ-ជម្រះសាលាដំបូងបំភ្លឺអំពីនីតិវិធីស្តីអំពីការប្រើប្រាស់ចម្លើយមុនៗ នៅក្នុងអំឡុងពេលនៃការសួរដេញដោលសាក្សី អង្គជំនុំជម្រះសូមបញ្ជាក់ថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវទទួលបាននូវច្បាប់ថតចម្លងនៃចម្លើយមុនៗរបស់ពួកគាត់ដែលបានផ្តល់ដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត មុនពេលពួកគាត់ចូលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ មុនពេលពួកគាត់ផ្តល់សក្ខីកម្ម អង្គជំនុំជម្រះនឹងសួរសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីថាតើ ពួកគាត់បានពិនិត្យឡើងវិញលើចម្លើយមុនៗរបស់ពួកគាត់ដែរឬទេ ហើយថាតើ ពួកគាត់អះអាងថា ចម្លើយទាំងនោះពិតជាត្រឹម

[17] សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ (អ.ជ.ត.ក) ឯកសារ F26 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៤។

[18] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ឯកសារ E336/3 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៦-២២។

[19] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ឯកសារ E336/3 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៧-១៨។

ត្រូវដែរឬយ៉ាងណា[20]។ បន្ទាប់មកទៀត ភាគីមិនគួរអានច្រើន ឬ ដដែលៗចេញពីចម្លើយបែបនេះ នៅក្នុងតុលាការទេ ហើយគួរតែយោងទៅលើចម្លើយមុនៗសម្រាប់តែគោលបំណងមានកម្រិតប៉ុណ្ណោះ ដូចជាធ្វើការបញ្ជាក់ ឬផ្តល់សេចក្តីលម្អិតបន្ថែមទៅលើព័ត៌មាននៅក្នុងចម្លើយទាំងនោះ រំឭកឡើងវិញនូវការចងចាំរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី និងសាកល្បងអំពីភាពអាចជឿជាក់បានរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី[21]។

**យោងនៅលើសំអាងហេតុដែលបានបញ្ជាក់ជូនខាងលើ អង្គជំនុំជម្រះសាលាដំបូង**

**បដិសេធ** សំណើរួមរបស់សហមេធាវីការពារក្តីទាំង ២ ក្រុម ទាំងស្រុង។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C * C.E.T.C.

**និល ណុន**

[20] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៧។

[21] ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ទំព័រ ៥៦ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា៖ "ការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយ ភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១" ឯកសារ E141 ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៧។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា៖ "ការប្រគល់ចម្លើយតបមុនៗឱ្យសាក្សីមុនពេលសាក្សីធ្វើសក្ខីកម្មនៅសវនាការ" ឯកសារ E141/1 ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ១។